# English for Study in Australia
# កម្មវិធីភាសាអង់គ្លេសសម្រាប់ការសិក្សានៅប្រទេសអូស្ត្រាលី

## LESSON 8 – Making Australian friends
## មេរៀនទី៨ ៖ ការចងមិត្តភាពជាមួយពលរដ្ឋអូស្ត្រាលី

| | |
|---|---|
| **L1 Male** | *សួស្តី ខ្ញុំបាទយុទ្ធឈាង ...* |
| **L1 Female** | *...ហើយខ្ញុំប៊ុន ឡឺវីសីដា មកពីវិទ្យុអូស្ត្រាលី។* |
| **L1 Male** | *សូមស្វាគមន៍លោក លោកស្រី និងប្រិយមិត្តជាថ្មីម្តងទៀតក្នុងកម្មវិធីសិក្សាភាសាអង់គ្លេសសម្រាប់ការសិក្សានៅប្រទេសអូស្ត្រាលីដែលចងក្រងឡើងដោយសេវាអប់រំពហុវប្បធម៌សម្រាប់មនុស្សពេញវ័យ (AMES) នៅទីក្រុងមែលប៊ិន ប្រទេសអូស្ត្រាលី។* |
| **L1 Female** | *កម្រងមេរៀនសិក្សាភាសាអង់គ្លេសទាំង២៦មេរៀននេះ នឹងជួយលោកអ្នក រៀបចំខ្លួនដើម្បីទៅសិក្សា និងរស់នៅក្នុងប្រទេសអូស្ត្រាលី។ លោកអ្នក នឹងមានការយល់ដឹងនូវចំណុចសំខាន់ៗនៃវប្បធម៌ និងដំណើរជីវិតសិក្សាក្នុងប្រទេសអូស្ត្រាលី ប្រសិនបើលោកអ្នកតាមដានស្តាប់និស្សិត អន្តរជាតិ៤នាក់ ដែលកំពុងសិក្សានៅក្នុងទីក្រុងមែលប៊ិន ប្រទេស អូស្ត្រាលី។* |
| | |
| **L1 Female** | *មេរៀនទី ៨ ៖ ការចងមិត្តភាពជាមួយពលរដ្ឋអូស្ត្រាលី*<br><br>*នៅក្នុងមេរៀននេះ លោកអ្នកនឹងរៀនអំពីការចាប់ផ្តើម ហើយបន្តកិច្ចសន្ទនាជាមួយមិត្តថ្មី ហើយយើងខ្ញុំនឹងចែករំលែកជាមួយលោកអ្នកនូវល្បិចអាថ៌កំបាំងដ៏ស័ក្តិសិទ្ធិក្នុងការចងមិត្តភាព។ លើសពីនេះ លោកអ្នក ក៏នឹងបានសិក្សាអំពីសារប្រយោជន៍នៃការថែរក្សាកំណត់ត្រាការសិក្សាផងដែរ។* |


© RadioAustralia/AMES 2008

| | |
|---|---|
| **L1 Male:** | *ឥឡូវនេះសូមចាប់ផ្តើមបាទ។ ជាដំបូងលោកអ្នក នឹងឮការសន្ទនាដោយមានការបកប្រែជូន។ លោកអ្នកនឹងមានឱកាសហាត់រៀនពាក្យពេចន៍ និងឃ្លាប្រយោគសំខាន់ៗ នៅក្នុងមេរៀននាពេលបន្តិចទៀតនេះ។ ក៏ប៉ុន្តែ ដើម្បីឲ្យឆាប់ចាំស្ទាត់ ខ្ញុំស្នើសុំឲ្យ លោកអ្នកហាត់អនុវត្តថាតាមការសន្ទនាទាំងមូល ដោយខ្លួនលោកអ្នកផ្ទាល់តែម្តង ពីព្រោះពាក្យពេជន៍ និងឃ្លាប្រយោគទាំងនេះ គឺជាការប្រើប្រាស់ភាសាអង់គ្លេសតាមបែបអូស្ត្រាលីសុទ្ធសាធតែម្តង ហើយលោកអ្នក ក៏អាចដកស្រង់ការសន្ទនានេះទាំងស្រុង ជាភាសាអង់គ្លេស ចេញពីវិបសាយថ៍របស់វិទ្យុអូស្ត្រាលីផងដែរ ។*<br>*នៅក្នុងមេរៀននេះ នាងអែនជល កំពុងស្រស់ស្រូបអាហារពេលព្រឹកជាមួយមិត្តរួមផ្ទះរបស់នាង ឈ្មោះ ឃែល។ អែនជល ចង់ហាត់អនុវត្តជំនាញសន្ទនាជាភាសាអង់គ្លេសមួយចំនួនជាមួយឃែល។* |
| | |
| Angel: | That’s a nice shirt, Kel. (LONG PAUSE. LESS CONFIDENT) I like that shade of blue. |
| L1: | *អ្ហ៎ា អាវនេះស្អាតណាស់ ឃែល។ ខ្ញុំចូលចិត្តពណ៌ខៀវបែបហ្នឹង។* |
| Kel:<br>NOT FRIENDLY | It’s just an old one. I haven’t done my laundry yet. |
| L1: | *នេះគ្រាន់តែជាអាវចាស់ទេតើ។ ខ្ញុំមិនទាន់បានបោកវាផង។* |
| | |
| Angel: | Anything interesting in the news today? |
| L1: | *តើមានព័ត៌មានអ្វីគួរឲ្យចាប់អារម្មណ៍ទេថ្ងៃនេះ?* |
| Kel: | (SIGHS IMPATIENTLY) It’s the *sports* section. (THEN CURTLY)<br>I think I’ll take it outside so I can read in quiet. |
| L1: | *មានតែព័ត៌មាន កីឡា ។*<br>*ខ្ញុំគិតថា ខ្ញុំចេញទៅអាននៅខាងក្រៅវិញល្អជាង ព្រោះខ្ញុំត្រូវការកន្លែងស្ងាត់ដើម្បីអាន។* |


© RadioAustralia/AMES 2008

| | |
|---|---|
| Angel:<br>(TAKEN ABACK) | Oh... Sorry. |
| L1: | អ្ហ៎... សុំទោសផង។ |
| | |
| Magda: | Wow, I’m puffed. I just did a ten k run. |
| L1: | អូយ ខ្ញុំហាត់ដល់ហើយនេះ។ ខ្ញុំទើបតែរត់បានចម្ងាយ១០គីឡូម៉ែត្រ អម្បាញ់មិញនេះឯង។ |
| Angel | Ten kilometers? |
| L1: | ថាម៉េច ១០គីឡូម៉ែត្រ? |
| | |
| Magda | Yeah. I’m trying to run more each week. |
| L1: | មែនហើយ។ ខ្ញុំកំពុងព្យាយាមរត់ឲ្យបានច្រើនឡើងៗនៅរៀងរាល់សប្ដាហ៍។ |
| | |
| Magda | Angel. Are you OK. You look like you’ve seen a ghost |
| L1: | អែនជល! តើនាងមិនអីទេមែនទេ។ មើលទៅមុខនាង ដូចជាទើបនឹងមាន រឿងអីមិនដឹងទេនេះ ។ |
| Angel:: | Nothing that bad. I was trying to make conversation with Kel and he just got up and left. |
| L1: | មិនមានបញ្ហាអ្វីធំដុំទេ។ គ្រាន់តែខ្ញុំព្យាយាមនិយាយលេងជាមួយ ឃែល ហើយគាត់ក៏ងើបដើរចេញទៅ។ |
| Magda: | What a creep. |
| L1: | ចំជាផ្តេសផ្តាសមែន។ |
| Angel: | I don’t understand it. It’s like he really doesn’t like me. |
| L1: | ខ្ញុំមិនយល់ទេ។ តែមើលទៅគាត់ដូចជាមិនចូលចិត្តខ្ញុំសោះ។ |
| Magda:: | Oh, Angel, it’s not you. He’s so unfriendly. I wish I could get rid of him but he was living here before I came. |


© RadioAustralia/AMES 2008

| | |
|---|---|
| L1: | *អូ៎ អែនជល មិនមែនមកពីនាងទេ។ ឃែល ជាមនុស្សឆ្មើង មិនរួសរាយជាមួយនរណាទេ។ ខ្ញុំមិនពេញចិត្តឲ្យគេនៅទីនេះទេ ប៉ុន្តែធ្វើម៉េចបើគេមករស់នៅទីនេះមុនខ្ញុំទៅទៀតនោះ។* |
| Angel: | I thought everyone in Australia was friendly. |
| L1: | *ខ្ញុំខំតែគិតថា មនុស្សគ្រប់គ្នានៅប្រទេសអូស្ត្រាលីជាមនុស្សរួសរាយរាក់ទាក់។* |
| Magda: | Most people are, but not everyone.  Just know that it's his problem, not yours. The best thing about him is that he's away most of the time. |
| L1: | *មនុស្សភាគច្រើននៅទីនេះ គឺរួសរាយរាក់ទាក់ តែមិនមែនទាំងអស់គ្នានោះទេ។ តែកុំខ្វល់ នោះជារឿងរបស់គាត់ មិនមែនជារឿងរបស់នាងនោះទេ។ អ្វីដែលល្អបំផុតចំពោះគាត់នោះ គឺគាត់ច្រើន**តែ**ចេញទៅក្រៅ។* |
| Angel: | I was trying out my conversation starters on him… but it didn't work. |
| L1: | *ខ្ញុំខំព្យាយាមផ្តើមការសន្ទនាជាមួយគាត់... ប៉ុន្តែ គ្មានបានផលប្រយោជន៍អីសោះ។* |
| Rocky: | Yeah, well, not everyone's as rude as Kel.  Do you want to practise your conversation starters with me? |
| L1: | *មែនហើយ ប្រហែលជាគ្មានអ្នកណាឈ្លើយដូច ឃែល ហ្នឹងទេ។ តើអ្នកចង់**ហាត់**និយាយ**ការ**ផ្តើម**កិច្ច**សន្ទនាជាមួយខ្ញុំទេ?* |
| Angel: | Yeah, thanks. |
| L1: | *ចាំសចង់ អរគុណ។* |
| Magda: | OK.  I'll pretend I'm a stranger.  We're at a barbecue in the park.  I'm sitting eating at a table. |
| L1: | *អូខេ។ ខ្ញុំនឹងដើរតួជាមនុស្សម្នាក់ដែលមិនដែលស្គាល់នាង។ ពួកយើងកំពុងអាំងសាច់បាប៊ីឃ្យូនៅ ឯសួនឧទ្យាន។ ខ្ញុំកំពុងអង្គុយញ៉ាំអាហារនៅនឹងតុមួយ។* |
| Angel: | OK.  (SHE GIVES A LITTLE COUGH) Excuse me, is that seat taken? |
| L1: | *អូយេ។ អត់ទោស តើកៅអីនេះមាននរណាអង្គុយហើយឬនៅ?* |
| Magda: | No.  Feel free. |


© RadioAustralia/AMES 2008

| | |
|---|---|
| L1: | *ទេអត់មានទេ យកចុះ។* |
| Angel: | Great day for a barbecue isn't it? |
| L1: | ថ្ងៃនេះគឺជាថ្ងៃដ៏ល្អសម្រាប់ការអាំងសាច់ មែនទេហ្អ៎? |
| Magda: | Yes. It's perfect. |
| L1: | *មែនហើយ។ ពិតជាល្អណាស់។* |
| Angel: | This food is delicious. |
| L1: | *ម្ហូបនេះឆ្ងាញ់ណាស់។* |
| Magda: | Yeah, have you tried the fried rice?  It's really spicy. |
| L1: | *ត្រូវហើយ តើអ្នកមានសាកញ៉ាំបាយឆាហើយឬនៅ? បាយឆាពិតជាហឹរឆ្ងាញ់ណាស់។* |
| Angel: | No, but I will.  I love spicy food. |
| L1: | *អត់ទាន់ផង ប៉ុន្តែខ្ញុំនឹងញ៉ាំ។ ព្រោះខ្ញុំចូលចិត្តម្ហូបណាដែលហឹរបែបហ្នឹង។* |
| Magda: | So do I. |
| L1: | *ខ្ញុំក៏អីចឹងដែរ។* |
| Angel: | I'm Angel by the way. |
| L1: | *និយាយអីចឹង ខ្ញុំឈ្មោះអែនជល។* |
| Magda: | Nice to meet you Angel, my name's Magda. |
| L1: | *រីករាយណាស់ដែលបានជួបនាង អែនជល ខ្ញុំឈ្មោះ ម៉េកដា។* |
| Angel: | What a coincidence!  My housemate's name is Magda! |
| L1: | *អីក៏ចៃដន្យល្អម្ល៉េះ! អ្នកនៅផ្ទះជាមួយខ្ញុំ គេក៏ឈ្មោះម៉េកដាដែរ។* |
| Magda: | Oh Angel, you're so funny. |
| L1: | *អ្ហ៎ អែនជល នាងពូកែនិយាយលេងណាស់។* |


© RadioAustralia/AMES 2008

| | |
|---|---|
| Angel: | That was fun! Thanks. |
| L1: | *ខ្ញុំគ្រាន់តែនិយាយឱ្យសប្បាយហ្នឹងណា៎! អរគុណ។* |
| Magda: | Your conversation was really good, Angel.  I think you’re going to make friends really easily. |
| L1: | *ការសន្ទនារបស់នាងពិតជាល្អណាស់អែនជល។ ខ្ញុំគិតថា នាងប្រាកដជាឆាប់មានមិត្តភក្តិច្រើន ជាក់ជាមិនខានឡើយ។* |
| Angel: | Thanks.  I hope so. |
| L1: | អរគុណហើយ។ ខ្ញុំក៏សង្ឃឹមអីចឹងដែរហ្នឹងណា៎។ |

ABC Radio Australia


© RadioAustralia/AMES 2008

**L1 Male:**

ការស្វែងយល់ពីកិច្ចសន្ទនា។ នៅក្នុងមេរៀនទី៦ យើងបានសិក្សាអំពីការចាប់ផ្តើមកិច្ចសន្ទនាមួយចំនួនជាមួយមិត្តភក្តិរបស់លោកអ្នក។ ប៉ុន្តែ តើលោកអ្នកគួរធ្វើយ៉ាងណាដើម្បីចាប់ផ្តើមកិច្ចសន្ទនាជាមួយនរណាម្នាក់ដែលលោកអ្នកមិនស្គាល់វិញនោះ? អ្វីដែលលោកអ្នកបានរៀនសូត្រដឹងពីដំបូងនៅទីនេះ គឺចង់បង្ហាញឲ្យលោកអ្នកជ្រាបថា ទោះជាលោកអ្នកព្យាយាមនិយាយរកជននោះខ្លាំងប៉ុណ្ណាក៏ដោយ ក៏ជួនកាលជនដែលយើងនិយាយទៅកាន់នោះ ពុំមានភាពរួសរាយតបមកវិញទាល់តែសោះ។ បញ្ហានេះកើតមានក្នុងប្រទេសអូស្ត្រាលី ក៏ដូចជានៅប្រទេសរបស់លោកអ្នកដែរ។ ជាទូទៅប្រជាជននៅក្នុងប្រទេសអូស្ត្រាលី មានឆន្ទៈឈឺឆ្អាលចង់ជួយណាស់ ប្រសិនបើលោកអ្នកសួរសំណួរអំពីទិសដៅ ឬលោកអ្នកត្រូវការជំនួយសម្រាប់លើកអីវ៉ាន់សំពីងសំពោងជាដើម ហើយជាធម្មតា ប្រជាជនអូស្ត្រាលីតែងនិយាយពាក្យថា សួស្តី។ ដោយហេតុនេះហើយ ទើបមានការចាត់ទុកថា ប្រជាជនអូស្ត្រាលី ជាប្រជាជនដែលរួសរាយរាក់ទាក់។ ទោះបីជាយ៉ាងណាក៏ដោយ ការស្វែងយល់អំពីមនុស្សម្នាទាំងពួង ឲ្យបានកាន់តែស៊ីជម្រៅ អាចមានការលំបាក។

តើការបង្កើតមិត្តភាពជាជាមួយជនជាតិអូស្ត្រាលីផ្តល់ផលប្រយោជន៍អ្វីខ្លះ? អត្ថប្រយោជន៍នោះ គឺលោកអ្នកនឹងមានឱកាសហាត់រៀនភាសាអង់គ្លេសកាន់តែច្រើនថែមទៀត។ លោកអ្នកនឹងបានស្តាប់យុវជនក្មេងៗ និយាយភាសាអង់គ្លេសផងដែរ។ មិនតែប៉ុណ្ណោះ លោកអ្នកនឹងបានហាត់រៀន ឃ្លាពេញនិយមនាពេលថ្មីៗក្នុងចំណោមយុវវ័យ។ គ្រួសារអូស្ត្រាលី ដែលលោកអ្នកមកស្នាក់នៅជាមួយ អាចពុំដឹងកន្លែងត្រូវទៅលេង ដែលលោកអ្នកពេញចិត្ត។ ដូច្នេះការបង្កើតមិត្តភាពជាមួយមិត្តភក្តិដែលមានវ័យស្របាល**នឹង**លោកអ្នក នឹងជួយឲ្យការស្នាក់នៅរបស់លោកអ្នក កាន់តែមានភាពប្រសើរឡើង និងធ្វើឲ្យលោកអ្នកទទួលបានបទពិសោធន៍ពីប្រទេសអូស្ត្រាលីកាន់តែច្រើនឡើងថែមទៀត។

ប៉ុន្តែ សូមលោកអ្នកកុំគិតថា ការបង្កើតមិត្តភាពនឹងកើតឡើងភ្លាមៗដូចចិត្តនោះ។ មិត្តភាពត្រូវការពេលវេលា។ លោកអ្នកមិនត្រូវសួរនរណាម្នាក់អំពី រឿងរ៉ាវផ្ទាល់ខ្លួនទេ លើកលែងតែលោកអ្នកស្គាល់ជននោះបានយូរគ្រប់គ្រាន់ ហើយលោកអ្នកអាចទុកចិត្តបាន។ ប្រសិនបើលោកអ្នកស្នាក់នៅក្នុងប្រទេសអូស្ត្រាលីក្នុងរយៈ ពេលខ្លី លោកអ្នកប្រហែលជាមិនអាចស្គាល់នរណាម្នាក់បានច្បាស់ឡើយ ប៉ុន្តែ លោកអ្នកក៏នៅតែអាចបង្កើតមិត្តភាពបានដែរ ហើយមិត្តភាពថ្មីនោះអាចនាំលោកអ្នកទៅកាន់ទីកន្លែងដែលលោកអ្នកគិតស្មានមិនដល់។ មិត្តភាពរបស់លោកអ្នកជាមួយជនជាតិអូស្ត្រាលី អាចនឹងនៅតែបន្តរីកចម្រើន បើទោះជាលោកអ្នកបានបែកពីពួកគេក៏ដោយ តាមរយៈអ៊ីនធើណិត ឬទូរស័ព្ទ។ ហើយហេតុការណ៍នេះពិតជាបានកើតមានឡើងមែន!


© RadioAustralia/AMES 2008

**L1 Female:**

*ម៉េកដា ជួយអែនជល ដោយឲ្យអែនជល ហាត់រៀនការផ្តើមកិច្ចសន្ទនា ។ ការចាប់ផ្តើមកិច្ចសន្ទនាជាមួយនរណាម្នាក់ ដែលលោកអ្នកមិនស្គាល់ គឺមិនមែនជាការលំបាកដូចដែលលោកអ្នកគិតឡើយ។ ជាបឋម ប្រសិនបើលោកអ្នកញញឹម ហើយមានអាកប្បកិរិយាប្រកបដោយការស្វាគមន៍នោះ លោកអ្នកនឹងជួយឱ្យដៃគូម្ខាងទៀតមានចិត្តចង់និយាយបកមកលោកអ្នកវិញ។ ការបញ្ចេញស្នាមញញឹមរបស់លោកអ្នក គួរប្រព្រឹត្តទៅតាមសម្រួល ដោយបង្ហាញពីចំណង់ចំណូលចិត្តចង់និយាយអ្វីមួយ ហើយ**មិន**ត្រូវក្រពាត់ដៃឬក៏អោបដៃរបស់លោកអ្នកឡើយ។ នៅពេលលោកអ្នកជួបនរណាម្នាក់ជាលើកដំបូង លោកអ្នក ត្រូវចេះអង្កេតពីកែវភ្នែករបស់មនុស្សនោះ ដោយកត់សម្គាល់ក្នុងចិត្តនូវពណ៌ភ្នែករបស់ជននោះ។  ការធ្វើដូចនេះ តម្រូវឲ្យលោកអ្នកសម្លឹងចំកែវភ្នែកដៃគូសន្ទនារបស់លោកអ្នក។ នៅពេលលោកអ្នកណែនាំខ្លួន សូមយកចិត្តទុកដាក់ទៅលើឈ្មោះរបស់មនុស្សដែលលោកអ្នកនិយាយជាមួយ និងត្រូវចងចាំឈ្មោះនោះឲ្យបាន។ បន្ទាប់មកទៀត តើលោកអ្នកត្រូវនិយាយអំពីអ្វី? អែនជល បានផ្តល់ឧទាហរណ៍យ៉ាងល្អមួយចំនួន ដូចដែលនាងលើកឡើងថា នាងចូលចិត្តសម្លៀកបំពាក់របស់ យៃល នាងសួរថាកៅអីទំនេរឬទេ ឬនាងបង្ហាញការចាប់អារម្មណ៍ទៅលើអ្វីៗ ដែលមាននៅជុំវិញខ្លួន ដូចជាម្ហូបអាហារជាដើម។ ប្រសិនបើលោកអ្នកឈរនិយាយ លោកអ្នកមិនត្រូវឈរ ក្នុងចម្ងាយជិតជាងមួយម៉ែត្រកន្លះនោះទេ។ ប្រជាជនអូស្ត្រាលី ចូលចិត្តគម្លាតនៅពេលឈរនិយាយគ្នា។ លោកអ្នក ត្រូវរក្សាការសម្លឹងចំកែវភ្នែកឲ្យបានប្រមាណ ៧០ភាគរយ នៅគ្រប់ពេលនៃការសន្ទនាទាំងអស់។ ការសម្លឹងដៃគូសន្ទនាមុតពេកដោយមិនដាក់ភ្នែកសោះ អាចធ្វើឲ្យដៃគូនោះ មានអារម្មណ៍មិនស្រួល  ដែលនាំឲ្យមានការភ័យខ្លាចដោយមិនចាំបាច់ ហើយសំណួរ**សាមញ្ញ**របស់**លោក**អ្នក អាចនឹងក្លាយទៅ**ជាការចោទសួរចម្លើយទៅវិញ។***

*សូមស្វែងរកចំណុចដែលមានចំណង់ចំណូលចិត្តដូចគ្នា។ ភាពផ្ទុយគ្នានៃចំណង់ចំណូលចិត្តអាចនាំដល់ការទាក់ទាញខ្លះដែរ ប៉ុន្តែ លោកអ្នកគួរចងចាំថា ជាទូទៅមិត្តភាពមានអាយុកាលយូរអង្វែង ដោយសារតែចំណង់ចំណូលចិត្តប្រហាក់ប្រហែលគ្នា។*

*ជាបន្តទៀតនេះ គឺជាអាថ៌កំបាំងដ៏ស័ក្តិសិទ្ធិក្នុងការបង្កើតមិត្តភាព។ ចូរបង្ហាញចំណាប់អារម្មណ៍ពិតប្រាកដរបស់លោកអ្នក ចំពោះមនុស្សដទៃទៀត និងសូមកុំបង្ហាញឲ្យគេឃើញថា លោកអ្នកចង់ឲ្យពួកគេមានចំណាប់អាម្មណ៍មកលើរូបលោកអ្នកឲ្យសោះ។*

*សូមស្តាប់នូវចំណុចសំខាន់នៃការសន្ទនាពីសំណាក់ដៃគូសន្ទនា និងបន្តសន្ទនាលើចំណុចសំខាន់នោះ។ ប្រសិនបើការសន្ទនានិយាយពីការសិក្សា ចូរសួរសំណួរបន្ទាប់ទាក់ទងនឹងការសិក្សា។ ប្រសិនបើ**ដៃគូសន្ទនារបស់**លោកអ្នកនិយាយអំពីគ្រួសារ សូមសួរសំណួរបន្ថែមទៀតអំពីគ្រួសាររបស់ដៃគូសន្ទនា មុនពេលលោកអ្នក ចាប់ផ្តើមនិយាយរឿងរ៉ាវផ្ទាល់ខ្លួនរបស់លោកអ្នក ប្រាប់ដល់ដៃគូសន្ទនានោះ។*


© RadioAustralia/AMES 2008

| | |
|---|---|
| **1 Male:** | *ការហាត់រៀនភាសា។*<br>*ថ្ងៃនេះ យើងនឹងហាត់រៀនអំពី**ការ**ផ្ដើមកិច្ចសន្ទនា ការប្រើប្រាស់ពាក្យពេចន៍គោល និង ការបញ្ចប់ ដើម្បីជួយលោកអ្នកក្នុងការបង្កើតមិត្តភាពជាមួយពលរដ្ឋអូស្ត្រាលី។*<br>*ជាដំបូង លោកអ្នកនឹងឮការបកប្រែ បន្ទាប់មកសូមស្ដាប់ រួចថាតាមជាភាសាអង់គ្លេស។* |

| | |
|---|---|
| **L1:** | *អត់ទោស តើកន្លែងនេះមាននរណាអង្គុយហើយឬនៅ?* |
| **English:** | Excuse me, is this seat taken? (PAUSE) |
| **L1:** | *ខ្ញុំពិតជាស្រឡាញ់កន្សែងបង់ករបស់អ្នកណាស់។ តើវាផលិតពីសរសៃសូត្រមែនទេ?* |
| **English:** | I really like your scarf. Is it silk? (PAUSE) |
| **L1:** | *តើអ្នកធ្លាប់បានញ៉ាំសាច់ចៀមដែរឬទេ? សាច់វាឆ្ងាញ់ណាស់ណា៎។* |
| **English:** | Have you tried the lamb? It's delicious. (PAUSE) |
| **L1:** | *ថ្ងៃនេះជាថ្ងៃដ៏ល្អ មិនថាអីចឹងអ្ហេះ?* |
| **English:** | Isn't it a beautiful day? (PAUSE) |

| | |
|---|---|
| **L1:** | *តើអ្នកជាមិត្តភក្តិរបស់ប៉ៀរីមែនទេ?* |
| **English:** | Are you a friend of Barry's? (PAUSE) |
| **L1:** | *នៅក្នុងទីក្រុងនេះ តើមានកន្លែងណាខ្លះដែលអ្នកចូលចិត្ត?* |
| **English:** | What are your favourite places in this town? (PAUSE) |
| **L1:** | *ពិតមែនឬ? សូមប្រាប់ខ្ញុំថែមទៀតមកមើល។* |
| **English:** | Really? Tell me more. (PAUSE) |
| **L1:** | *មែនហើយ ខ្ញុំក៏គិតអីចឹងដែរ។* |


© RadioAustralia/AMES 2008

| | |
|---|---|
| **English:** | Yes, I think so too. (PAUSE) |
| **L1:** | *ពិតជារីករាយណាស់ដោយបានជួបអ្នក។* |
| **English:** | It was nice meeting you. (PAUSE) |
| **L1:** | *ពិតជាសប្បាយរីករាយណាស់ដោយបាននិយាយជាមួយអ្នក។* |
| **English:** | It’s been great talking to you. (PAUSE) |
| **L1:** | *ចាំជួបគ្នាម្តងទៀតនៅពេលណាមួយខាងមុខនេះ។* |
| **English:** | Let’s catch up again some time. (PAUSE) |

| | |
|---|---|
| **L1 Female:** | *ឥឡូវនេះ សូមស្តាប់និស្សិតនិយាយនៅតាមដងផ្លូវ!* |

| | |
|---|---|
| **Interviewer:** | *អត់ទោស?* |
| **Female Student:** | *ចាស៎ មានការអ្វីដែរ?* |
| **Interviewer:** | *តើនាងជាទេសចរនៅទីនេះមែនទេ?* |
| **Female Student:** | *ចា៎ស។* |
| **Interviewer:** | *តើនាងប្រកាន់ទេ ប្រសិនបើខ្ញុំសួរសំណួរមួយសម្រាប់វិទ្យុអូស្ត្រាលី?* |
| **Female Student:** | *មិនអីទេ សួរមកចុះ។* |
| **Interviewer:** | *តើនាងមានអ្វីដែលជាបទពិសោធន៍ទាក់ទងនឹងការចងមិត្តភាពក្នុងប្រទេស អូស្ត្រាលីនេះ ដែលនាងអាចប្រាប់ឲ្យពួកយើងបានដឹងផងនោះ?* |


© RadioAustralia/AMES 2008

| | |
|---|---|
| **Female Student:** | អ្ហ៎ ចាស! ថ្ងៃមួយ ខ្ញុំបានឡើងជិះឡានក្រុង ហើយបានសួរតៃកុងឡានឲ្យរកផ្លូវ “Robert Street” ។ គាត់ក៏បាននិយាយថា “តើអ្នកឯងនិយាយភាសាស្អីគេហ្នឹង ? និយាយអង់គ្លេសទៅមើល!”។ តៃកុងឡាននោះពិតជាគ្មានសុជីវធម៌អីបន្តិចសោះ។ ខ្ញុំមានការខ្មាស់អៀនមែនទែន។ ខ្ញុំមកទីនេះ មិនបានប៉ុន្មានផង ខ្ញុំស្ទើរតែស្រែកយំទៅហើយ។ ប៉ុន្តែ នារីម្នាក់ដែលអង្គុយនៅខាងមុខ បានញញឹមដាក់ខ្ញុំ។ ពេលនោះខ្ញុំពិតជាមានកម្លាំងចិត្តឡើងវិញ។ បន្ទាប់មក នាងក៏បានស្តីបន្ទោសតៃកុងឡាននោះ! នាងបានប្រាប់គាត់មិនឲ្យនិយាយបែបនេះចំពោះអ្នកធ្វើដំណើរ ហើយនាងនឹងរាយការណ៍អំពីអ្នកបើកឡានក្រុងនោះ។ |
| **Interviewer:** | តើគាត់មានបានសុំទោសនាងទេ? |
| **Female Student:** | គ្មានទេ ព្រោះនៅពេលនោះ មើលទៅមុខគាត់ ដូចជាម៉ូម៉ៅយ៉ាងម៉េចមិនដឹងទេ។ តែយ៉ាងណាក៏ដោយ នារីវ័យក្មេងនោះបានប្រាប់ខ្ញុំអំពីទីតាំងនៃផ្លូវ “Robert Street” ហើយយើងក៏ចាប់ផ្តើមជជែកគ្នា។ នាងជានិស្សិតសកលវិទ្យាល័យ ហើយនាងរស់នៅក្បែរកន្លែងដែលខ្ញុំស្នាក់នៅដែរ។ នៅពេលនោះហើយ ដែលខ្ញុំបានផ្តើមមិត្តភាព ជាមួយជនជាតិអូស្ត្រាលី។ ឥឡូវនេះ ពួកយើងជួបគ្នាញឹកញាប់ណាស់។ នាងក៏បាននាំខ្ញុំឲ្យស្គាល់កន្លែងសប្បាយៗមួយចំនួនផងដែរ។ |
| **Interviewer:** | នេះគឺជារឿងមួយល្អណាស់។ អរគុណហើយ។ |
| **Female Student:** | មិនអីទេចាស។ |


© RadioAustralia/AMES 2008

**L1 Male**

*តាមរយៈរឿងនេះ បង្កើតមិត្តភាពគឺជារឿងមួយមិនអាចស្មានទុកបានឡើយ។ ជាក់ស្តែងណាស់ ភាសាអង់គ្លេសរបស់និស្សិតម្នាក់នោះ អាចមានភាពច្បាស់លាស់ល្មម ដែលអាចឱ្យអ្នកជួយនាងយល់ពីនាងបាន។ តែតែកុងឡាននោះ ដូចជាមិនព្យាយាមស្វែងយល់តាមរយៈការបញ្ចេញសំឡេង***របស់នាងឡើយ។ លោកអ្នក***ប្រហែលជានឹងអាចជួបមនុស្សមានឥរិយាបថបែបនេះ នៅក្នុងប្រទេសណាមួយ ហើយបើលោកអ្នកជួបប្រទះរឿងបែបនេះមែននោះ សូមលោកអ្នកដើរចេញទៅឆ្ងាយ កុំយកចិត្តទុកដាក់គិតអំពីរឿងនោះឲ្យសោះ។*

*ប៉ុន្តែ យើងក៏គួរតែយល់បានដែរ ប្រសិនបើមនុស្សជាច្រើន មានការលំបាកក្នុងការស្តាប់ការបញ្ចេញសំឡេងរបស់លោកអ្នក នុះគឺដល់ពេលវេលាដែលលោកអ្នកត្រូវមើលសៀវភៅ ស្តាប់ខ្សែអាត់សំឡេង និងហាត់រៀនការបញ្ចេញសំឡេងរបស់លោកអ្នកហើយ។*

ABC Radio Australia


© RadioAustralia/AMES 2008

**EXERCISE**
លំហាត់

**L1 Female:**

ទំលាប់ដ៏ប្រពៃសម្រាប់ការសិក្សា។ សូមធ្វើការថ្លឹងថ្លែងនិងរក្សានូវតុល្យភាពរវាងការសិក្សា និងការរស់នៅក្នុងសង្គមរបស់លោកអ្នក។ សូមរៀបគម្រោងការសិក្សារបស់លោកអ្នក និងសរសេរកំណត់ត្រានៃការសិក្សា ប៉ុន្តែត្រូវប្រាកដក្នុងចិត្តថា នោះជាគម្រោងជាក់ស្តែង ដែលអាចយកទៅអនុវត្តបាន។

Study diary ឬសៀវភៅកំណត់ត្រានៃការសិក្សារបស់លោកអ្នក គួរបង្ហាញនូវម៉ោងពេលសិក្សាជាទូទៅនៅក្នុងថ្នាក់រៀនឲ្យបានច្បាស់លាស់។ ប្រសិនបើលោកអ្នកមានសៀវភៅកំណត់ត្រាហើយ សូមកត់ត្រាអំពីពេលវេលាដែលលោកអ្នកត្រូវស្វ័យសិក្សានៅក្នុងបណ្ណាល័យ កិច្ចការដែលគ្រូដាក់ឲ្យធ្វើនៅផ្ទះ រាប់បញ្ចូលទាំងការងារ ក្រៅម៉ោងផងដែរ។ សូមដាក់ជាសញ្ញាជួយរំលឹកលើកំណត់ត្រាការសិក្សាផ្សេងៗគ្នា និងសូមអនុវត្តផែនការនៃសិក្សារបស់លោកអ្នក ឲ្យបាន**ហ្មត់ចត់**ទៀងទាត់ផង។

ប្រសិនបើ លោកអ្នកទទួលបានសំបុត្រអញ្ជើញ ដែល**ប៉ះនឹង**ម៉ោងសិក្សាដែលលោកអ្នកបានគ្រោងទុកនោះ ហើយសំបុត្រនោះមិនអាចលើកពេលចូលរួមបានទេនោះ សូមលោកអ្នកទទួលយកសំបុត្រនោះចុះ ប៉ុន្តែត្រូវរៀនសងឲ្យបានពេញម៉ោងវិញនៅពេលក្រោយ។

សូមរក្សាកំណត់ត្រារបស់លោកអ្នកនៅក្នុងដូស្សេរក្សាឯកសារ ដែលលោកអ្នកយកមកសាលារៀនរាល់ថ្ងៃ ដើម្បីងាយស្រួលរកមើល។

**L1 Male:**

ឥឡូវនេះ យើងខ្ញុំសូមជូនឱវាទចុងក្រោយ ដែលអាចជាជំនួយក្នុងការបង្កើតមិត្តភាពជាមួយពលរដ្ឋអូស្ត្រាលី ឬជាមួយជាតិសាសន៍ដទៃទៀត។ ប្រសិនបើលោកអ្នកជាសិស្សសកលវិទ្យាល័យ លោកអ្នកអាចចូលរួមក្នុងក្លឹបជាច្រើន ដូចជា ក្លឹបលេងអុក ក្លឹបរាំ ក្លឹបកីឡាគ្រប់ប្រភេទ មានដូចជា ជិះស្គីបាល់ទាត់ វាយប៉េងប៉ុងជាដើម។ល។ ក្នុងពេលចូលរួមក្នុងក្លឹប **លោកអ្នក**ធ្វើអ្វីដែលលោកអ្នកចូលចិត្ត គឺជាវិធីដ៏ល្អបំផុត ដែលលោកអ្នកអាចជួបជាមួយជនជាតិអូស្ត្រាលី និងមនុស្សដទៃទៀត ដែលមានចំណង់ចំណូលចិត្តដូចលោកអ្នក។


© RadioAustralia/AMES 2008

| | |
|---|---|
| **L1 Female:** | *ឧបសគ្គក្នុងការប្រើប្រាស់ភាសា។ នៅក្នុងមេរៀននេះ យើងនឹងហាត់អនុវត្តក្រុមព្យញ្ជនៈនៅខាងចុងនៃពាក្យ។ អ្នកដែលមិននិយាយភាសាអង់គ្លេសមួយចំនួន មានការលំបាកក្នុងការបញ្ចប់ពាក្យនៅខាងចុង ដែលពាក្យទាំងនោះតម្រូវឲ្យមានការបន្ថែមសំឡេងបន្តិច មានដូចជា* "lunch" *ទៅជា* "luncha"*។*<br>*ឥឡូវនេះ សូមលោកអ្នកហាត់រៀនពាក្យពេចន៍មួយចំនួន។ សូមស្តាប់ រួចថាតាម។* |

| | |
|---|---|
| **English:** | lunch (PAUSE)<br>church (PAUSE)<br>last (PAUSE)<br>sports (PAUSE)<br>ask (PAUSE)<br>hand (PAUSE)<br>perfect (PAUSE)<br>slept (PAUSE)<br>friend (PAUSE)<br>thanks (PAUSE) |

| | |
|---|---|
| **L1 Female:** | *ហើយឥឡូវនេះដល់ពេលហាត់ពត់អណ្តាតរបស់លោកអ្នកទៀតហើយចាស។ សូមស្តាប់ រួចថាតាមឱ្យបានច្រើនដងតាមដែលអាចធ្វើទៅបាន។* |

| | |
|---|---|
| English: | Thanks for lunch. It was perfect. (PAUSE)<br>Thanks for lunch. It was perfect. (PAUSE) |

ABC Radio Australia | ABC Radio Australia


© RadioAustralia/AMES 2008

**L1 Male:**

*មេរៀនទី៨ឥឡូវនេះ ឈានចូលដល់ទីបញ្ចប់ហើយបាទ។ សូមលោកអ្នករង់ចាំស្តាប់កម្មវិធីភាសាអង់គ្លេស សម្រាប់ការសិក្សានៅប្រទេសអូស្ត្រាលីមេរៀនទី៩ទៀតស្តីអំពី “ផ្ទាក់រៀននៅអូស្ត្រាលី” នៅក្នុងកម្មវិធីក្រោយទៀតបាទ។ចំពោះមិត្តស្តាប់ដែលចង់បានមេរៀនថ្ងៃនេះ ព្រមទាំងឯកសារជំនួយមេរៀន ក៏ដូចជាលំហាត់សម្រាប់មេរៀននេះ លោកអ្នកអាចចូលទៅ វ៉ិបសាយថ៍របស់វិទ្យុអូស្ត្រាលី ដែលមានអាសយដ្ឋានដូចតទៅនេះ radioaustralia.net.au/khmer*

*កម្មវិធីភាសាអង់គ្លេសសម្រាប់ការសិក្សានៅអូស្ត្រាលីនេះចងក្រងឡើងដោយសេវាអប់រំពហុវប្បធម៌សម្រាប់មនុស្សពេញវ័យ នៅទីក្រុង មែលប៊ិន ប្រទេសអូស្ត្រាលី។ ចំពោះឯកសារ និងព័ត៌មានទាក់ទងនឹងការសិក្សាភាសាអង់គ្លេស ផ្សេងៗទៀតរបស់សេវាអប់រំពហុវប្បធម៌សម្រាប់មនុស្សពេញវ័យ លោកអ្នក អាចបើកមើល វ៉ិបសាយថ៍ ames.net.au ។*

ចប់មេរៀនទី៨

ABC Radio Australia



© RadioAustralia/AMES 2008